ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

*ថ្ងៃ ពុធ ០៤ កើត ខែ មិគសិរ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥*
*រាជធានីភ្នំពេញ, ថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០២១*

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងហិរញ្ញប្បទានសហប្រតិបត្តិការ រវាងរាជរដ្ឋាភិបាល និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB)

នាថ្ងៃពុធ ៤ កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោង ១០:៣០ នាទីព្រឹក, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង លោក Anthony Robert Gill នាយកស្តីទីស្ថានតំណាងធនាគារអភិវឌ្ឍន៍អាស៊ី ប្រចាំកម្ពុជា បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងហិរញ្ញប្បទានសហប្រតិបត្តិការចំនួន ៥ សម្រាប់គម្រោង/កម្មវិធី ចំនួន ៤ ដែលមានទឹកប្រាក់សរុបចំនួន ៣៣២,០៥ លានដុល្លារអាមេរិក÷ ***១) កម្មវិធីអភិវឌ្ឍវិស័យហិរញ្ញវត្ថុប្រកបដោយបរិយាប័ន្ន (អនុកម្មវិធីទី៣), ២) គម្រោងទប់ស្កាត់ និងបង្ការជំងឺឆ្លងក្នុងមហាអនុតំបន់មេគង្គ -ហិរញ្ញប្បទានបន្ថែម, ៣) គម្រោង កែលម្អបណ្តាញផ្លូវជាតិ ជំហានទី២, និង ៤) គម្រោងអភិវឌ្ឍន៍ទីក្រុងតូចឱ្យចង់រស់នៅ ។***

***១- កម្មវិធីអភិវឌ្ឍវិស័យហិរញ្ញវត្ថុប្រកបដោយបរិយាប័ន្ន (អនុកម្មវិធីទី៣)÷***

គ្រោងចំណាយថវិកាសរុប ៤០ លាន ដុល្លារអាមេរិក ក្នុងគោលបំណងបន្ត និងគាំទ្រការអនុវត្តកម្មវិធីកំណែទម្រង់សំខាន់ៗជាអាទិភាពក្នុងវិស័យហិរញ្ញវត្ថុ ដូចមានចែងក្នុងយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ២០១៦-២០២៥ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០១៩-២០២៣ ឱ្យកាន់តែរឹងមាំ និងផ្អែកលើគោលការណ៍ទីផ្សារ ដែលបម្រើឱ្យការកៀរគរ និងបែងចែកធនធានហិរញ្ញវត្ថុប្រកបដោយ ប្រសិទ្ធភាព គាំទ្រដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងកាត់បន្ថយភាពក្រីក្រមួយកម្រិតទៀត តាមរយៈការបង្កើន លទ្ធភាពទទួលបានកម្ចីសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម (MSMEs) ក្នុងដំណាក់កាលក្រោយវិបត្តិកូវីដ-១៩, ការធ្វើឱ្យ ប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ និងការអនុវត្តកំណែទម្រង់វិស័យហិរញ្ញវត្ថុប្រកបដោយស្ថិរភាព។ កម្មវិធីនេះ នឹងគាំទ្រជាចម្បងទៅលើ÷ (១) ការពង្រីក

សេវាកម្មហិរញ្ញវត្ថុឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋក្រីក្រ; (២) ការពង្រឹង ស្ថិរភាពវិស័យហិរញ្ញវត្ថុ; និង (៣) ការពង្រឹងហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធហិរញ្ញវត្ថុ ។

*២- ហិរញ្ញប្បទានបន្ថែមសម្រាប់គម្រោងទប់ស្កាត់ និងបង្ការជំងឺឆ្លងក្នុងមហាអនុតំបន់មេគង្គ÷*

គ្រោងចំណាយ ថវិកាសរុប ៣៥ លានដុល្លារអាមេរិក ក្នុងនោះ ហិរញ្ញប្បទានសម្បទានពី ADB ចំនួន ២៥ លានដុល្លារអាមេរិក ហិរញ្ញប្បទានឥតសំណងពីមូលនិធិជប៉ុនសម្រាប់កាត់បន្ថយភាពក្រីក្រ (JFPR) ចំនួន ៥ លានដុល្លារអាមេរិក និងការចូលរួមជាថវិកាបដិភាគចំនួន ៥ លានដុល្លារអាមេរិក សម្រាប់បន្តពង្រីកសកម្មភាពទប់ស្កាត់ និងបង្ការជំងឺឆ្លង រួមទាំងជំងឺ COVID-19 ឱ្យបានគ្រប់ ២៥ រាជធានី-ខេត្តរបស់កម្ពុជា ដោយពង្រីកសកម្មភាពបន្ថែមក្នុងរាជធានី-ខេត្តគោលដៅចំនួន ១១ បន្ថែមលើ ខេត្តគោលដៅកំពុងអនុវត្តចំនួន ១៤ នឹងគាំទ្រលើសកម្មភាពសំខាន់ៗចំនួន ០៣ រួមមាន÷ (១) ការពង្រឹងប្រព័ន្ធតាមដាន និងឆ្លើយតបនឹងជំងឺឆ្លង, (២) ការលើកកម្ពស់សេវាមន្ទីរពិសោធន៍ និងមន្ទីរពេទ្យក្នុងការបង្ការ និងព្យាបាលជំងឺឆ្លង, និង (៣) ការពង្រឹងសមត្ថភាពក្នុងការត្រៀម និងឆ្លើយតបជាបន្ទាន់នឹងជំងឺ COVID-19 ។

*៣- គម្រោងកែលម្អបណ្តាញផ្លូវជាតិ ដំណាក់កាលទី ២÷*

គ្រោងចំណាយថវិកាសរុប ៩០ លានដុល្លារអាមេរិក ក្នុងនោះ ហិរញ្ញប្បទានសម្បទានពី ADB ចំនួន ៨២,០៥ លានដុល្លារអាមេរិក និងការចូលរួមជាថវិកាបដិភាគចំនួន ៧,៩៥ លានដុល្លារអាមេរិក សម្រាប់បង្កើនប្រសិទ្ធភាពនៃការដឹកជញ្ជូនតាមច្រករបៀងសេដ្ឋកិច្ចភាគខាងត្បូងនៃមហាអនុតំបន់ មេគង្គ តាមរយៈ ការកែលម្អផ្លូវជាតិលេខ ២៣ និងផ្លូវលេខ ៣១២ ក្នុងខេត្តកណ្តាល និងខេត្តព្រៃវែង នឹងផ្តោតសំខាន់លើ (១) កែលម្អផ្លូវជាតិ និងផ្លូវខេត្ត ឱ្យមានភាពធន់នឹងបម្រែបម្រួលអាកាសធាតុ, និង (២) ការពង្រឹងការត្រួតពិនិត្យលើការ ដឹកជញ្ជូនលើសទម្ងន់ ។

*៤- គម្រោងអភិវឌ្ឍន៍ទីក្រុងគួរឱ្យចង់រស់នៅ÷*

គ្រោងចំណាយថវិកាសរុប ១៩៣,៥ លានដុល្លារអាមេរិក ក្នុងនោះ ហិរញ្ញប្បទានសម្បទានពី ADB ចំនួន ១៨០ លានដុល្លារអាមេរិក និងការចូលរួមជាថវិកាបដិភាគចំនួន ១៣,៥០ លានដុល្លារអាមេរិក សម្រាប់គាំទ្រការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន និងចីរភាពសម្រាប់ក្រុងបាវិត កំពត និងប៉ោយប៉ែត តាមរយៈការសាងសង់ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធគ្រប់គ្រងទឹកកខ្វក់, និងប្រព័ន្ធគ្រប់គ្រងសំរាម និងសំណល់រឹង ព្រមទាំងការកាត់បន្ថយមហន្តរាយដោយគ្រោះទឹកជំនន់តាមរយៈការពង្រឹងសមត្ថភាពក្នុងការរៀបចំផែនការអភិវឌ្ឍន៍ទីក្រុង។ គម្រោងនេះ នឹងគាំទ្រចម្បងលើ ១) ការកែលម្អក្របខ័ណ្ឌគោលនយោបាយ វិធាន និងបទប្បញ្ញត្តិ, ២) ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីក្រុង, និង ៣) ការលើក កម្ពស់ប្រសិទ្ធភាព និង អភិបាលកិច្ចស្ថាប័ន ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានរំលឹកឡើងវិញអំពីកិច្ចសហប្រតិបត្តិការ ADB ដែលបាន ផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការសរុបចំនួនប្រមាណ ៤,៣០ ប៊ីលានដុល្លារអាមេរិក ដោយគិតបញ្ចូលទាំងកិច្ចព្រមព្រៀង ចំនួន ០៥ ដែលបានចុះហត្ថលេខាក្នុងថ្ងៃនេះ ដែលក្នុងនោះ ឥណទានសម្បទានមានទឹកប្រាក់សរុបចំនួន

ប្រមាណ ៣,៧៥ ប៊ីលានដុល្លារអាមេរិក សម្រាប់អនុវត្តកម្មវិធី/គម្រោងចំនួន ១២៣ និងហិរញ្ញប្បទានឥតសំណង មានទឹកប្រាក់សរុបចំនួន ប្រមាណ ៥១៦ លានដុល្លារអាមេរិក សម្រាប់អនុវត្តកម្មវិធី/គម្រោងចំនួន ៦៤ ។ ទាំងនេះបង្ហាញពីការប្តេជ្ញាបន្តពង្រឹង ភាពជាដៃគូដ៏រឹងមាំរបស់ ADB ជាមួយរាជរដ្ឋាភិបាលកម្ពុជា ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសមានចិត្ត និងសុភវិនិច្ឆ័យរបស់ ADB ដែលបានផ្តល់ការជឿទុកចិត្ត និងជឿជាក់លើការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈការអនុម័តផ្តល់ហិរញ្ញប្បទានសម្រាប់គម្រោងខាងលើ និងបានវាយតម្លៃខ្ពស់ចំពោះតួនាទីដ៏សំខាន់របស់ដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលបានរួមចំណែកយ៉ាងធំធេងក្នុងការអភិវឌ្ឍនៅកម្ពុជា សំដៅកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និងបែងចែកផ្លែផ្កានៃកំណើនប្រកបដោយសមធម៌ដល់គ្រប់ស្រទាប់វណ្ណៈ នៃប្រជាជន តាមរយៈការបន្តធានាសម្រេចឱ្យបាននូវចីរភាពនៃកំណើនសេដ្ឋកិច្ចក្នុងរយៈពេលវែង និងឆ្ពោះទៅរកវិបុលភាព ។